# ព្រះរាជក្រម

នស/រកម/០៤០៥/០០៨

## យើង

## ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់ យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋា-ភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើធម្មនុញ្ញអង្គការអន្តរជាតិទេសន្តរប្រវេសន៍ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ២ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើ
# ធម្មនុញ្ញអង្គការអន្តរជាតិទេសន្តរប្រវេសន៍

**មាត្រា ១.-**

អនុម័តយល់ព្រមលើធម្មនុញ្ញអង្គការអន្តរជាតិទេសន្តរប្រវេសន៍ ដែលធ្វើនៅទីក្រុងហ្សឺណែវ នាថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ១៩៥១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តធម្មនុញ្ញអង្គការអន្តរជាតិទេសន្តរប្រវេសន៍នេះ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចាស.០៥០៤.១៧៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ហត្ថលេខា និងព្រះហស្តលេខា
ស ខេង នរោត្តម សិរីវុឌ្ឍ

ស្រេង ១៥៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សាឌី តាន់

៣/៣

# ធម្មនុញ្ញ

# អង្គការអន្តរជាតិទេសន្តរប្រវេសន៍

Constitution de l'Organisation Internationale pour les Migrations (OIM)

Constitution of the International Organization for Migration (IOM)

# មាតិកា

ទំព័រ


បុព្វកថា......................................................................៣

ជំពូកទី ១ : គោលបំណង និង មុខងារ..................................៥

ជំពូកទី ២ : សមាជិកភាព..................................................៦

ជំពូកទី ៣ : អង្គការចាត់តាំង...............................................៧

ជំពូកទី ៤ : ក្រុមប្រឹក្សា.......................................................៧

ជំពូកទី ៥ : គណៈកម្មាធិការប្រតិបត្តិ.......................................៩

ជំពូកទី ៦ : រដ្ឋបាល..........................................................១២

ជំពូកទី ៧ : ទីស្នាក់ការ......................................................១៣

ជំពូកទី ៨ : ហិរញ្ញវត្ថុ.......................................................១៣

ជំពូកទី ៩ : លក្ខន្តិកៈគតិយុត្ត..............................................១៤

ជំពូកទី ១០ : បទប្បញ្ញត្តិផ្សេងៗ.............................................១៥

# ធម្មនុញ្ញ (*)

## បុព្វកថា

## ភាគីជាសមាជិកទាំងឡាយ

### ដោយរំលឹកឡើងវិញពី

សេចក្ដីសំរេចចិត្ត ដែលបានអនុម័តកាលពីថ្ងៃ ០៥ ខែធ្នូ ឆ្នាំ១៩៥១ ដោយសន្និសីទស្ដីពី ទេសន្តរប្រវេសន៍ (Migrations) នៅទីក្រុងប្រ៊ុយសែល ។

### ដោយទទួលស្គាល់ថា

-ការផ្ដល់ជូននូវសេវាកម្មទេសន្តរប្រវេសន៍នៅកំរិតអន្តរជាតិ តែងតែត្រូវការជាចាំបាច់ដើម្បីធានាឱ្យដំណើរការនៃចលនាទេសន្តរប្រវេសន៍ប្រព្រឹត្តទៅប្រកបដោយសណ្ដាប់ធ្នាប់នៅទូទាំងពិភពលោកនិងដើម្បីសំរួលក្នុងលក្ខខណ្ឌដ៏គាប់ប្រសើរបំផុតនូវការដោះស្រាយ និងការធ្វើសមាហរណកម្មទេសន្តរប្រវេសន្ត (Migrants) ទៅក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមរបស់ប្រទេសដែលទទួល (Pays d'accueil) ។

-សេវាកម្មសន្តរប្រវេសន៍ ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា អាចជាតំរូវការចាំបាច់ផងដែរចំពោះការធ្វើទេសន្តរប្រវេសន៍បណ្ដោះអាសន្ន ការធ្វើទេសន្តរប្រវេសន៍ត្រលប់មកវិញ និងការធ្វើទេសន្តរប្រវេសន៍ក្នុងតំបន់ ។

-ទេសន្តរប្រវេសន៍អន្តរជាតិ រួមមានជនភៀសខ្លួន ជនផ្លាស់ប្ដូរទីកន្លែង និងជនដទៃទៀតដែលត្រូវបានបង្ខំឱ្យចាកចេញពីទឹកដីកំណើតខ្លួន ហើយដែលត្រូវការចាំបាច់នូវសេវាកម្មទេសន្តរប្រវេសន៍អន្តរជាតិ ។

-វាជាការចាំបាច់ដែលត្រូវជំរុញឱ្យមានកិច្ចសហប្រតិបត្តិការរវាងរដ្ឋនិងបណ្ដាអង្គការអន្តរជាតិទាំងឡាយដើម្បីសំរួលដល់ការធ្វើនិរប្រវេសន៍ (Emigration) របស់ជនទាំងឡាយ ដែលមានបំណងចង់ទៅកាន់ប្រទេសដទៃដែលនៅទីនោះពួកគេអាចទទួលបាននូវការពឹងផ្អែកលើខ្លួនឯងបានតាមរយៈការងារ និងអាចរស់នៅជាមួយក្រុមគ្រួសារក្នុងស្ថានភាពសមរម្យ និងក្នុងលក្ខណៈថ្លៃថ្នូរ ។

-ទេសន្តរប្រវេសន៍ អាចជំរុញឱ្យមានការបង្កើតនូវឱកាសសេដ្ឋកិច្ចថ្មីៗក្នុងរដ្ឋទទួល ហើយទំនាក់ទំនងមួយនឹងកើតមានរវាងទេសន្តរប្រវេសន៍ និងលក្ខខណ្ឌសេដ្ឋកិច្ច សង្គម និងវប្បធម៌ ក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍។

-តំរូវការនានារបស់រដ្ឋកំពុងអភិវឌ្ឍន៍ គួរតែត្រូវបានពិចារណាចំពោះកិច្ចសហប្រតិបត្តិការ និងសកម្មភាពអន្តរជាតិដ៏ទៃទៀតដែលពាក់ព័ន្ធនឹងការធ្វើទេសន្តរប្រវេសន៍។

-វាជាការចាំបាច់ដែលត្រូវជំរុញឱ្យមានកិច្ចសហប្រតិបត្តិការរវាងរដ្ឋ និងអង្គការអន្តរជាតិ អង្គការរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ដើម្បីធ្វើការស្រាវជ្រាវ និងពិគ្រោះយោបល់អំពីបញ្ហាទេសន្តរប្រវេសន៍ដែលទាក់ទងមិនត្រឹមតែដំណើរការទេសន្តរប្រវេសន៍ (Migration) ប៉ុណ្ណោះទេ ប៉ុន្តែរួមបញ្ចូលទាំងស្ថានភាព និងតំរូវការជាក់ស្តែងផ្សេងៗរបស់ទេសន្តរប្រវេសន្ត (Migrants) ដែលជាមនុស្សម្នាក់ផងដែរ។

-ចលនារបស់ទេសន្តរប្រវេសន្ត (Migrants) គួរតែត្រូវបានរ៉ាប់រងដោយមានសេវាកម្មដឹកជញ្ជូនធម្មតា ហើយក្នុងករណីចាំបាច់ អាចទទួលស្គាល់ថាមានសេវាកម្មបន្ថែម ឬផ្សេងពីនេះ។

-កិច្ចសហប្រតិបត្តិការ និងការសំរបសំរួលយ៉ាងជិតស្និទ្ធរវាងរដ្ឋ អង្គការអន្តរជាតិ អង្គការរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ស្ដីពីបញ្ហាទេសន្តរប្រវេសន៍ និងជនភៀសខ្លួន គឺជាការចាំបាច់។

-ការផ្តល់ហិរញ្ញវត្ថុចំពោះសកម្មភាពទាក់ទងនឹងបញ្ហាទេសន្តរប្រវេសន៍ គឺជាការចាំបាច់។

## សំរេចបង្កើត

អង្គការអន្តរជាតិទេសន្តរប្រវេសន៍ ដែលតទៅនេះហៅថា "អង្គការ" ហើយព្រមទទួលយកធម្មនុញ្ញនេះ ៗ

---

(*) អត្ថបទនៃធម្មនុញ្ញនេះ បញ្ចូលក្នុងធម្មនុញ្ញចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ១៩៥៣ របស់គណៈកម្មាធិការអន្តររដ្ឋាភិបាលសំរាប់ទេសន្តរប្រវេសន៍អឺរ៉ុប ( ឈ្មោះពីមុននៃអង្គការទេសន្តរប្រវេសន៍អន្តរជាតិ ) នូវវិសោធនកម្មដែលបានអនុម័តនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៨៧ និងចូលជាធរមាននៅថ្ងៃទី ១៤ ខែ វិច្ឆកា ឆ្នាំ ១៩៨៩។

# ជំពូកទី ១
# គោលបំណង និង មុខងារ

## មាត្រា ១

១-គោលបំណង និងមុខងាររបស់អង្គការគឺ :

ក-ចាត់វិធានការចាំបាច់ទាំងអស់ដើម្បីធានាការផ្ទេរទេសន្តរប្រវេសន្ត (Migrants) ទៅបណ្តាប្រទេសផ្សេងៗដែលផ្តល់ឱកាសសំរាប់ការធ្វើទេសន្តរប្រវេសន៍ ដែលមានរបៀបរៀបរយដល់ជនទាំងឡាយណាដែលមិនមានលទ្ធភាពគ្រប់គ្រាន់ ឬដែលមិនអាចធ្វើទេសន្តរប្រវេសន៍ដោយគ្មានជំនួយពិសេស ។

ខ-ទទួលរ៉ាប់រងរៀបចំការផ្ទេរជនភៀសខ្លួន ជនផ្លាស់ប្តូរទីកន្លែង និងជនទាំងឡាយណាដែលកំពុងត្រូវការសេវាកម្មទេសន្តរប្រវេសន៍អន្តរជាតិ តាមរយៈការរៀបចំចាត់ចែងរវាងអង្គការ និងរដ្ឋដែលពាក់ព័ន្ធ ដោយរួមបញ្ចូលទាំងរដ្ឋទាំងឡាយ ដែលសន្យាទទួលយកអ្នកទាំងនោះ ។

គ-ផ្តល់ទៅតាមសំណើ និងដោយមានការព្រមព្រៀងជាមួយរដ្ឋដែលពាក់ព័ន្ធ នូវសេវាកម្មទេសន្តរ-ប្រវេសន៍ ដូចជា ការប្រមូលទេសន្តរប្រវេសន្ត (Migrants) ការជ្រើសរើសទេសន្តរប្រវេសន្ត ការរៀបចំការធ្វើទេសន្តរប្រវេសន៍ ការបណ្តុះបណ្តាលភាសា សកម្មភាពតំរង់ទិស ការត្រួតពិនិត្យសុខភាព ការរកការងារឱ្យធ្វើ សកម្មភាពផ្សេងៗដែលជួយសំរួលការទទួល និងការធ្វើសមាហរណ-កម្ម សេវាកម្មពិគ្រោះយោបល់ស្តីពី បញ្ហាទេសន្តរប្រវេសន៍ ព្រមទាំងជំនួយដ៏ទៃទៀតដែលស្របតាមគោលបំណងរបស់អង្គការ ។

ឃ-ផ្តល់សេវាកម្មប្រហាក់ប្រហែលគ្នា តាមសំណើរបស់រដ្ឋ ឬ ដោយសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិដ៏ទៃទៀតដែលមានការចាប់អារម្មណ៍សំរាប់ការធ្វើទេសន្តរប្រវេសន៍ត្រលប់មកវិញដោយស្ម័គ្រចិត្ត និងរួមទាំងការធ្វើមាតុភូមិនិវត្តន៍ដោយស្ម័គ្រចិត្ត។

ង-ផ្តល់វេទិការសំរាប់រដ្ឋ អង្គការអន្តរជាតិ និងបណ្តាអង្គការដ៏ទៃទៀត ដើម្បីធ្វើការផ្លាស់ប្តូរទស្សនៈ និង បទពិសោធន៍គ្នាទៅវិញទៅមក និងដើម្បីជំរុញកិច្ចសហប្រតិបត្តិការ និងការសំរបសំរួលការខិតខំប្រឹងប្រែងអន្តរជាតិស្តីពី បញ្ហាទេសន្តរប្រវេសន៍អន្តរជាតិរួមបញ្ចូលទាំងការសិក្សាអំពីបញ្ហាទាំងនេះ ដើម្បីធ្វើឱ្យមានការចំរើននូវដំណោះស្រាយទាំងឡាយដែលអាចយកមកអនុវត្តបាន។

២-ក្នុងការអនុវត្តនីមុខងាររបស់ខ្លួន អង្គការធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយបណ្តាអង្គការអន្តរជាតិ អង្គការរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងបញ្ហាទេសន្តរប្រវេសន៍ ជនភៀសខ្លួន និងធនធាន-មនុស្ស ក្នុងគោលបំណងជួយដល់ការសំរបសំរួលសកម្មភាពអន្តរជាតិក្នុងវិស័យទាំងនេះ។ កិច្ចសហប្រតិបត្តិការបែបនេះ គួរតែត្រូវបានអនុវត្តដោយមានការគោរពគ្នាទៅវិញទៅមក នូវសមត្ថកិច្ចរបស់អង្គការផ្សេងៗដែលពាក់ព័ន្ធ។

៣-អង្គការទទួលស្គាល់ថា លក្ខណៈនៃប្រវេសន៍ (Critères d'admission) និងចំនួននៃអន្តោប្រវេសន្ត (Immigrants) ដែលអនុញ្ញាតឱ្យចូលរដ្ឋណាមួយ គឺជាបញ្ហាស្ថិតនៅក្រោមក្នុងយុត្តាធិការ ឬដែនសមត្ថកិច្ចជាតិរបស់រដ្ឋណាមួយ ហើយក្នុងការបំពេញមុខងាររបស់ខ្លួន អង្គការគោរពទៅតាមច្បាប់ និងបទបញ្ញា ព្រមទាំងគោលនយោបាយរបស់រដ្ឋដែលពាក់ព័ន្ធ។

# ជំពូកទី ២
# សមាជិកភាព

## មាត្រា ២

ជាសមាជិករបស់អង្គការគឺ :

ក-បណ្តារដ្ឋទាំងឡាយ ដែលជាសមាជិករបស់អង្គការ ដែលបានព្រមទទួលយកធម្មនុញ្ញនេះ យោងតាមមាត្រា ៣៤ ឬ ដែលបានអនុវត្តតាមលក្ខខណ្ឌនៃមាត្រា ៣៥។

ខ-បណ្តារដ្ឋដទៃទៀត ដែលបានបង្ហាញពីការចាប់អារម្មណ៍ចំពោះគោលការណ៍ធ្វើដំណើរដោយសេរីរបស់បុគ្គល ហើយដែលចូលរួមវិភាគទានហិរញ្ញវត្ថុយ៉ាងហោចណាស់ចំពោះការចំណាយផ្នែករដ្ឋបាលរបស់អង្គការ ដែលអត្រានៃការរួមវិភាគទាននោះ នឹងត្រូវមានការយល់ព្រមរវាងក្រុមប្រឹក្សា និងរដ្ឋដែលពាក់ព័ន្ធ និងដោយផ្អែកលើសេចក្តីសំរេចភាគច្រើនពីរភាគបីរបស់ក្រុមប្រឹក្សា និងក្រោយពីរដ្ឋនោះព្រមទទួលយកធម្មនុញ្ញនេះ។

## មាត្រា ៣

រដ្ឋជាសមាជិកទាំងឡាយ អាចផ្តល់ការជូនដំណឹង ស្តីពីការដកខ្លួនពីអង្គការនៅចុងឆ្នាំសារពើពន្ធ។ ការជូនដំណឹងនេះត្រូវសរសេរជាលាយល័ក្ខអក្សរ និងត្រូវបញ្ជូនឱ្យដល់អគ្គនាយករបស់អង្គការយ៉ាងហោចណាស់ ៤ ខែ

មុនការបញ្ចប់ឆ្នាំសារពើពន្ធ។ កាតព្វកិច្ចហិរញ្ញវត្ថុចំពោះអង្គការរបស់រដ្ឋជាសមាជិកណាមួយ ដែលបានផ្តល់ការជូនដំណឹងស្តីពីការដកខ្លួន នឹងត្រូវអនុវត្តពេញមួយឆ្នាំសារពើពន្ធនៃឆ្នាំដែលការជូនដំណឹងនេះត្រូវបានធ្វើ។

## មាត្រា ៤

១-បើសិនរដ្ឋជាសមាជិកណាមួយ មិនបានបំពេញកាតព្វកិច្ចហិរញ្ញវត្ថុរបស់ខ្លួនចំពោះអង្គការសំរាប់រយៈពេលពីរឆ្នាំសារពើពន្ធជាប់គ្នា ក្រុមប្រឹក្សា ផ្អែកតាមរយៈសេចក្តីសំរេចភាគច្រើនពីរភាគបី អាចផ្អាកសិទ្ធិបោះឆ្នោត និងសេវាកម្មទាំងអស់ ឬ មួយផ្នែក ដែលរដ្ឋជាសមាជិកនោះបានទទួល។ ក្រុមប្រឹក្សា មានអំណាចផ្តល់សិទ្ធិបោះឆ្នោត និងសេវាកម្មនេះឡើងវិញ ដោយសេចក្តីសំរេចតាមសំលេងភាគច្រើនធម្មតា។

២-រដ្ឋជាសមាជិកណាមួយ អាចត្រូវបានផ្អាកពីសមាជិកភាពដោយសេចក្តីសំរេចភាគច្រើនពីរភាគបីរបស់ក្រុម-ប្រឹក្សា ប្រសិនជាខ្លួនរំលោភដោយមានះនូវគោលការណ៍នៃធម្មនុញ្ញនេះ។ ក្រុមប្រឹក្សាមានអំណាចផ្តល់សមាជិក-ភាពនេះវិញបាន ដោយសេចក្តីសំរេចតាមសំលេងភាគច្រើនធម្មតា។

# ជំពូកទី ៣
# អង្គការចាត់តាំងផ្សេងៗ

## មាត្រា ៥

អង្គការចាត់តាំងផ្សេងៗរបស់អង្គការអន្តរជាតិសំរាប់ទេសន្តរប្រវេសន៍គឺ :

ក-ក្រុមប្រឹក្សា

ខ-គណៈកម្មាធិការប្រតិបត្តិ

គ-រដ្ឋបាល

# ជំពូកទី ៤
# ក្រុមប្រឹក្សា

## មាត្រា ៦

មុខងាររបស់ក្រុមប្រឹក្សាបន្ថែមលើមុខងារដែលមានចែងនៅក្នុងបទប្បញ្ញត្តិផ្សេងៗទៀតនៃធម្មនុញ្ញនេះគឺ :

ក-កំណត់គោលនយោបាយរបស់អង្គការ។

Reviewed by OUCH CHANSORA Ministry of Interior

ខ-ត្រួតពិនិត្យរបាយការណ៍ អនុម័ត និងតំរង់ទិសសកម្មភាពរបស់គណៈកម្មាធិការប្រតិបត្តិ ។

គ-ត្រួតពិនិត្យរបាយការណ៍ អនុម័ត និងតំរង់ទិសសកម្មភាពរបស់អគ្គនាយក ។

ឃ-សិក្សា និងអនុម័តកម្មវិធី ថវិកា ការចំណាយ និងគណនេយ្យរបស់អង្គការ ។

ង-ចាត់វិធានការសមរម្យផ្សេងទៀត ដើម្បីសំរេចឱ្យបាននូវគោលបំណងរបស់អង្គការ ។

## មាត្រា ៧

១-សមាសភាពរបស់ក្រុមប្រឹក្សា រួមមានអ្នកតំណាងទាំងឡាយរបស់រដ្ឋជាសមាជិក ។

២-រដ្ឋជាសមាជិកនីមួយៗ ត្រូវចាត់តាំងឱ្យមានតំណាងម្នាក់ និងអ្នកជំនួស ព្រមទាំងទីប្រឹក្សាមួយចំនួនទៅតាមការចាំបាច់ ។

៣-រដ្ឋជាសមាជិកនីមួយៗ មានសំលេងឆ្នោតមួយនៅក្នុងក្រុមប្រឹក្សា ។

## មាត្រា ៨

ក្រុមប្រឹក្សា អាចអនុញ្ញាតឱ្យរដ្ឋមិនមែនជាសមាជិក និងអង្គការអន្តរជាតិ អង្គការរដ្ឋាភិបាល ឬមិនមែនរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងបញ្ហាទេសន្តរប្រវេសន៍ ជនភៀសខ្លួន ឬធនធានមនុស្ស ចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួនក្នុងឋានៈជាអ្នកសង្កេតការណ៍ ទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងវិធាននីតិវិធីរបស់ខ្លួនបន្ទាប់ពីពួកគេបានដាក់ពាក្យស្នើសុំ ។ អ្នកសង្កេតការណ៍ទាំងនេះ មិនមានសិទ្ធិបោះឆ្នោតឡើយ ។

## មាត្រា ៩

១-ក្រុមប្រឹក្សាជួបប្រជុំក្នុងកិច្ចប្រជុំសាមញ្ញម្តងក្នុង១ ឆ្នាំ ។

២-ក្រុមប្រឹក្សាត្រូវជួបប្រជុំក្នុងកិច្ចប្រជុំវិសាមញ្ញតាមសំណើរបស់ :

ក-សមាជិករបស់ខ្លួនចំនួនមួយភាគបី

ខ-គណៈកម្មាធិការប្រតិបត្តិ

គ-អគ្គនាយក ឬប្រធានក្រុមប្រឹក្សាក្នុងកាលៈទេសៈបន្ទាន់ ។

៣-នៅពេលចាប់ផ្តើមកិច្ចសម័យប្រជុំសាមញ្ញនីមួយៗ ក្រុមប្រឹក្សាត្រូវបោះឆ្នោតជ្រើសរើសប្រធាន និងសមាជិកការិយាល័យដទៃទៀតសំរាប់អណត្តិ ១ ឆ្នាំ ។

## មាត្រា ១០

ក្រុមប្រឹក្សាអាចបង្កើតអនុគណៈកម្មាធិការផ្សេងៗដែលចាំបាច់ដើម្បីបំពេញមុខងាររបស់ខ្លួនឱ្យបានសមរម្យ ។

## មាត្រា ១១

ក្រុមប្រឹក្សាត្រូវអនុម័តវិធាននីតិវិធីផ្ទាល់របស់ខ្លួន ។

# ជំពូកទី ៥
# គណៈកម្មាធិការប្រតិបត្តិ

## មាត្រា ១២

មុខងាររបស់គណៈកម្មាធិការប្រតិបត្តិគឺ :

ក-ពិនិត្យ និងត្រួតពិនិត្យឡើងវិញនូវគោលនយោបាយ កម្មវិធី និងសកម្មភាពរបស់អង្គការ របាយការណ៍ប្រចាំឆ្នាំរបស់អគ្គនាយក និងរបាយការណ៍ពិសេសណាមួយ ។

ខ-ពិនិត្យបញ្ហាហិរញ្ញវត្ថុ ឬថវិកាណាមួយ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

គ-ពិចារណាបញ្ហាណាមួយដែលក្រុមប្រឹក្សាបានលើកឡើងជាពិសេសចំពោះខ្លួន រួមមានការត្រួតពិនិត្យថវិកាឡើងវិញ និងចាត់វិធានការចំពោះបញ្ហានេះប្រសិនបើក្នុងករណីចាំបាច់ ។

ឃ-ផ្តល់ប្រឹក្សាចំពោះបញ្ហាណាមួយ ដែលអគ្គនាយកដាក់ជូន ។

ង-ធ្វើសេចក្តីសំរេចជាបន្ទាន់ណាមួយនៅចន្លោះសម័យប្រជុំក្រុមប្រឹក្សា ស្តីពីបញ្ហាដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ហើយដែលសេចក្តីសំរេចនេះ នឹងត្រូវយកទៅសុំការអនុម័តយល់ព្រមពីក្រុមប្រឹក្សានៅសម័យប្រជុំលើកក្រោយ ។

ច-ផ្តល់ការណែនាំ ឬសំណើទៅឱ្យក្រុមប្រឹក្សា ឬអគ្គនាយក ស្តីពីគំនិតផ្តួចផ្តើមផ្ទាល់របស់ខ្លួន ។

ឆ-បញ្ជូនរបាយការណ៍ និង/ឬ អនុសាសន៍ផ្សេងៗទៅកាន់ក្រុមប្រឹក្សា អំពីបញ្ហាដែលពាក់ព័ន្ធ ។

## មាត្រា ១៣

១-សមាសភាពរបស់គណៈកម្មាធិការប្រតិបត្តិ រួមមានអ្នកតំណាងរបស់រដ្ឋជាសមាជិកចំនួន ៩ ។ ចំនួននេះអាចត្រូវបានបង្កើនដោយសេចក្តីសំរេចតាមសំលេងភាគច្រើនពីរភាគបីរបស់ក្រុមប្រឹក្សា តែចំនួននេះមិនត្រូវលើសពីមួយភាគបីនៃសមាជិកសរុបរបស់អង្គការ ។

២-រដ្ឋជាសមាជិកទាំងនេះត្រូវបានបោះឆ្នោតជ្រើសរើសដោយក្រុមប្រឹក្សាសំរាប់រយៈពេលពីរឆ្នាំ និងមានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសសារជាថ្មីបាន ។

៣-សមាជិកនីមួយៗរបស់គណៈកម្មាធិការប្រតិបត្តិត្រូវមានតំណាងម្នាក់ និងអ្នកជំនួស ព្រមទាំងទីប្រឹក្សាមួយ-ចំនួនទៅតាមការចាំបាច់ ។

៤-សមាជិកនីមួយៗរបស់គណៈកម្មាធិការប្រតិបត្តិមានសំលេងឆ្នោតមួយ ។

## មាត្រា ១៤

១-គណៈកម្មាធិការប្រតិបត្តិ ជួបប្រជុំគ្នាយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ ។ គណៈកម្មាធិការនេះជួបប្រជុំគ្នាក្នុងបំណងបំពេញមុខងាររបស់ខ្លួន តាមសំណើរបស់ :

ក-ប្រធានរបស់ខ្លួន

ខ-ក្រុមប្រឹក្សា

គ-អគ្គនាយកក្រោយពីបានពិគ្រោះយោបល់ជាមួយប្រធានក្រុមប្រឹក្សា

ឃ-សមាជិករបស់ខ្លួនភាគច្រើន ។

២-គណៈកម្មាធិការប្រតិបត្តិត្រូវបោះឆ្នោតជ្រើសរើសប្រធានមួយរូប និង អនុប្រធានមួយរូប ពីក្នុងចំណោមសមាជិករបស់ខ្លួនសំរាប់អណត្តិ ១ ឆ្នាំ ។

## មាត្រា ១៥

ដោយស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សា គណៈកម្មាធិការប្រតិបត្តិអាចបង្កើតអនុគណៈកម្មាធិការផ្សេងៗដែលចាំបាច់ដើម្បីបំពេញមុខងាររបស់ខ្លួនឱ្យបានសមរម្យ ។

## មាត្រា ១៦

គណៈកម្មាធិការប្រតិបត្តិ ត្រូវអនុម័តវិធាននីតិវិធីផ្ទាល់របស់ខ្លួន ។

# ជំពូកទី ៦
# រដ្ឋបាល

## មាត្រា ១៧

សមាសភាពរបស់រដ្ឋបាលរួមមាន អគ្គនាយកមួយរូប អគ្គនាយករងមួយរូប និងបុគ្គលិកទៅតាមការកំណត់របស់ក្រុមប្រឹក្សា ។

## មាត្រា ១៨

១-អគ្គនាយក និងអគ្គនាយករង ត្រូវបានបោះឆ្នោតជ្រើសរើសដោយសំលេងភាគច្រើនពីរភាគបីនៃក្រុមប្រឹក្សា និងអាចត្រូវបានបោះឆ្នោតជ្រើសរើសម្តងទៀតបាន ។ អណត្តិនៃការកាន់តំណែងរបស់អ្នកទាំងនេះជាធម្មតាមានរយៈពេល ៥ ឆ្នាំ ប៉ុន្តែក្នុងករណីលើកលែង អាចមានរយៈពេលតិចជាងនេះតាមការសំរេចដោយសំលេងភាគច្រើនពីរភាគបីរបស់ក្រុមប្រឹក្សា ។ ពួកគេត្រូវបំរើការងារតាមរបៀបកិច្ចសន្យាដែលបានអនុម័តយល់-ព្រមដោយក្រុមប្រឹក្សា ហើយត្រូវបានចុះហត្ថលេខាក្នុងនាមអង្គការដោយប្រធានក្រុមប្រឹក្សា ។

២-អគ្គនាយក ត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សា និងគណៈកម្មាធិការប្រតិបត្តិ ។ អគ្គនាយក ត្រូវបំពេញមុខងាររដ្ឋបាល និងប្រតិបត្តិរបស់អង្គការស្របទៅតាមធម្មនុញ្ញនេះ គោលនយោបាយ និងសេចក្តីសំរេចរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការប្រតិបត្តិ ព្រមទាំងវិធាន និងបទបញ្ជាផ្សេងៗ ដែលបង្កើតដោយក្រុមប្រឹក្សា និងគណៈកម្មាធិការប្រតិបត្តិ ។ អគ្គនាយក ត្រូវរៀបចំសំណើផ្សេងៗសំរាប់ក្រុមប្រឹក្សាចាត់វិធានការសមស្រប ។

## មាត្រា ១៩

អគ្គនាយក ត្រូវតែងតាំងបុគ្គលិករដ្ឋបាលស្របទៅតាមលក្ខន្តិកៈស្តីពី បុគ្គលិកដែលបានអនុម័តដោយក្រុមប្រឹក្សា ។

## មាត្រា ២០

១-ក្នុងការអនុវត្តនីភារកិច្ចរបស់ខ្លួន អគ្គនាយក អគ្គនាយករង និងបុគ្គលិក មិនស្វែងរក ឬទទួលការណែនាំផ្សេងៗពីរដ្ឋណាមួយ ឬពីអាជ្ញាធរណាមួយនៅក្រៅអង្គការឡើយ។ ពួកគេត្រូវជៀសវាងពីគ្រប់សកម្មភាពទាំងអស់ដែលមានលក្ខណៈវិសមិតភាពជាមួយនឹងតួនាទីខ្លួនជាមន្ត្រីអន្តរជាតិ។

២-រដ្ឋជាសមាជិកនីមួយៗ ត្រូវគោរពលក្ខណៈជាអន្តរជាតិដាច់ដោយឡែកនៃមុខងារ និងការទទួលខុសត្រូវរបស់អគ្គនាយក អគ្គនាយករង និងបុគ្គលិកទាំងអស់ ហើយមិនត្រូវជះឥទ្ធិពលលើការអនុវត្តនីការទទួលខុសត្រូវរបស់ពួកគេឡើយ ។

៣-ប្រសិទ្ធិភាព សមត្ថភាព និងគុណភាពនៃបូរណៈភាពរបស់បុគ្គល គឺជាបញ្ហាដែលត្រូវពិចារណាក្នុងការជ្រើសរើស និងជួលបុគ្គលិក ដែលនឹងត្រូវបានជ្រើសរើសពីក្នុងចំណោមជនជាតិនៃរដ្ឋជាសមាជិករបស់អង្គការដោយពិចារណាលើគោលការណ៍នៃការបែងចែកតាមភូមិសាស្ត្រស្មើៗគ្នា លើកលែងតែក្នុងកាលៈទេសៈពិសេសណាមួយ។

## មាត្រា ២១

អគ្គនាយក ឬត្រូវតំណាងដោយអគ្គនាយករង ឬមន្ត្រីដែលត្រូវជ្រើសតាំងម្នាក់ ត្រូវមានវត្តមាននៅគ្រប់សម័យប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការប្រតិបត្តិ និងអនុគណៈកម្មាធិការណាមួយ។ អគ្គនាយក ឬតំណាងដែលបានជ្រើសតាំង អាចចូលរួមក្នុងកិច្ចពិភាក្សាផ្សេងៗ ប៉ុន្តែមិនអាចបោះឆ្នោតបានឡើយ។

## មាត្រា ២២

បន្ទាប់ពីសម័យប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ដែលប្រព្រឹត្តទៅក្រោយពេលបញ្ចប់ឆ្នាំសារពើពន្ធ អគ្គនាយកត្រូវធ្វើរបាយការណ៍អំពីការងារជូនក្រុមប្រឹក្សាតាមរយៈគណៈកម្មាធិការប្រតិបត្តិ ដែលរបាយការណ៍នោះមានសេចក្តីរាយការណ៍លំអិតអំពីសកម្មភាពរបស់អង្គការក្នុងរយៈពេលមួយឆ្នាំកន្លងមក។

# ជំពូកទី ៧
# ទីស្នាក់ការ

## មាត្រា ២៣

១-អង្គការមានទីស្នាក់ការរបស់ខ្លួននៅទីក្រុងហ្សឺណែវ ។ ក្រុមប្រឹក្សាអាចសំរេចផ្លាស់ប្តូរទីតាំងនេះបានតាមរយៈការបោះឆ្នោតយកសំលេងភាគច្រើនពីរភាគបី ។

២-កិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការប្រតិបត្តិ ត្រូវធ្វើនៅទីក្រុងហ្សឺណែវ ប្រសិនបើសមាជិកយ៉ាងតិចពីរភាគបីរបស់ក្រុមប្រឹក្សា ឬគណៈកម្មាធិការប្រតិបត្តិ មិនសំរេចថាជួបប្រជុំនៅកន្លែងផ្សេងទេ ។

# ជំពូកទី ៨
# ហិរញ្ញវត្ថុ

## មាត្រា ២៤

អគ្គនាយកដាក់ជូនក្រុមប្រឹក្សាពិនិត្យ តាមរយៈគណៈកម្មាធិការប្រតិបត្តិ នូវថវិកាប្រចាំឆ្នាំដែលរួមមានចំណាយរដ្ឋបាល និងប្រតិបត្តិការ និងចំណូលគ្រោងទុក ការគ្រោងទុកជាមុនបន្ថែមផ្សេងៗទៀតដែលចាំបាច់ និងរបាយការណ៍គណនេយ្យប្រចាំឆ្នាំ ឬពិសេសរបស់អង្គការ ។

## មាត្រា ២៥

១- ចំណូលចាំបាច់សំរាប់ការចំណាយផ្សេងៗរបស់អង្គការ បានមក :

ក-សំរាប់ផ្នែកថវិការដ្ឋបាល គឺដោយការរួមវិភាគទានជាសាច់ប្រាក់ពីបណ្តារដ្ឋជាសមាជិក ដែលត្រូវបង់នៅពេលចាប់ផ្តើមឆ្នាំសារពើពន្ធនីមួយៗដែលពាក់ព័ន្ធ ហើយដែលការបង់វិភាគទាននេះត្រូវធ្វើឱ្យបានទាន់ពេលវេលា ។

ខ-សំរាប់ផ្នែកថវិកាប្រតិបត្តិការ គឺដោយការរួមវិភាគទានជាសាច់ប្រាក់ ជាសំភារៈ ឬជាសេវាកម្មពីបណ្តារដ្ឋជាសមាជិក រដ្ឋមិនមែនសមាជិក អង្គការអន្តរជាតិ អង្គការរដ្ឋាភិបាល ឬមិនមែន-

រដ្ឋាភិបាល អង្គភាពដែលច្បាប់ទទួលស្គាល់ ឬបុគ្គលឯកជននានា ហើយដែលវិភាគទានទាំងនេះត្រូវបង់ទាំងអស់ និងឱ្យបានឆាប់រហ័សមុនពេលផុតកំណត់ឆ្នាំសារពើពន្ធនីមួយៗដែលពាក់ព័ន្ធ ។

២-បណ្តារដ្ឋជាសមាជិក ត្រូវរួមវិភាគទានថវិកាផ្នែករដ្ឋបាលរបស់អង្គការ ដោយផ្អែកទៅតាមអត្រាមួយដែលមានការព្រមព្រៀងរវាងក្រុមប្រឹក្សា និងរដ្ឋជាសមាជិកដែលពាក់ព័ន្ធ ។

៣-ការរួមវិភាគទានចំពោះការចំណាយផ្នែកប្រតិបត្តិការរបស់អង្គការ ត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត ហើយអ្នកដែលចូលរួមវិភាគទានចំពោះថវិកាផ្នែកប្រតិបត្តិការ អាចកំណត់ជាមួយអង្គការនូវលក្ខខណ្ឌផ្សេងៗ ស្តីពីការប្រើប្រាស់ប្រាក់វិភាគទានឱ្យស្របតាមគោលបំណង និងមុខងាររបស់អង្គការ ។

៤-ក).ការចំណាយផ្នែករដ្ឋបាលរបស់ទីស្នាក់ការទាំងអស់ និងការចំណាយផ្នែករដ្ឋបាលដទៃទៀតទាំងអស់ ត្រូវបានចាត់ទុកថាជាថវិកាផ្នែករដ្ឋបាល លើកលែងតែការចំណាយទាំងឡាយដែលកើតមានដោយការអនុវត្តតាមមុខងារដែលបានបញ្ជាក់ក្នុងកថាខ័ណ្ឌ ១ (គ) និង (ឃ) នៃមាត្រា ១ ។

ខ).ការចំណាយផ្នែកប្រតិបត្តិការទាំងអស់ និងការចំណាយផ្នែករដ្ឋបាល ដែលកើតមានដោយអនុវត្តតាមមុខងារដែលបានបញ្ជាក់ក្នុងកថាខ័ណ្ឌ ១ (គ) និង (ឃ) នៃមាត្រា ១ នឹងត្រូវចាត់ទុកថាជាថវិកាផ្នែកប្រតិបត្តិការ ។

៥-ក្រុមប្រឹក្សាត្រូវធានាថា ការគ្រប់គ្រងថវិកា នឹងធ្វើឡើងក្នុងលក្ខណៈមួយដែលមានការសន្សំសំចៃ និងមានប្រសិទ្ធិភាពខ្ពស់ ។

## មាត្រា ២៦

បទបញ្ជាស្តីពីហិរញ្ញវត្ថុទាំងឡាយ ត្រូវបានបង្កើតដោយក្រុមប្រឹក្សា ។

# ជំពូកទី ៩
# លក្ខន្តិកៈគតិយុត្ត

## មាត្រា ២៧

អង្គការមានបុគ្គលភាពគតិយុត្តរបស់ខ្លួន ។ អង្គការមានសមត្ថភាពគតិយុត្តចាំបាច់ ដើម្បីអនុវត្តមុខងារ និងសំរេចបាននូវគោលបំណងរបស់ខ្លួន ហើយជាពិសេស យោងទៅតាមច្បាប់របស់រដ្ឋនីមួយៗ មានសមត្ថភាព :

(ក) ដើម្បីចុះកិច្ចសន្យា . (ខ) ដើម្បីទទួលចលនៈវត្ថុ និងអចលនៈវត្ថុ និងប្រើប្រាស់វា . (គ) ដើម្បីទទួល និងសងមូលនិធិសាធារណៈ និងឯកជន . (ឃ) ដើម្បីធ្វើបណ្តឹងទៅតុលាការ ។

## មាត្រា ២៨

១-អង្គការមានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដែលចាំបាច់ដើម្បីអនុវត្តមុខងារ និងសំរេចគោលបំណងរបស់ខ្លួន ។

២-អ្នកតំណាងទាំងឡាយរបស់រដ្ឋជាសមាជិក អគ្គនាយក អគ្គនាយករង និង បុគ្គលិករដ្ឋបាល ក៏ទទួលបាននូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដូចគ្នានេះដែរ ដែលចាំបាច់ដើម្បីអនុវត្តដោយឯករាជ្យនូវមុខងាររបស់ពួកគេទាក់ទងនឹងអង្គការ ។

៣-បុព្វសិទ្ធិ និងអភ័យឯសិទ្ធិទាំងនេះ ត្រូវកំណត់នៅក្នុងកិច្ចព្រមព្រៀងរវាងអង្គការ និងរដ្ឋដែលពាក់ព័ន្ធនានា ឬ តាមរយៈវិធានការផ្សេងៗដែលរដ្ឋទាំងនេះលើកឡើង ។

# ជំពូកទី ១០
# បទប្បញ្ញត្តិផ្សេងៗ

## មាត្រា ២៩

១-សេចក្តីសំរេចទាំងអស់របស់ក្រុមប្រឹក្សា គណៈកម្មាធិការប្រតិបត្តិ និងអនុគណៈកម្មាធិការ នឹងត្រូវបានអនុម័តដោយសំលេងឆ្នោតភាគច្រើនធម្មតា លើកលែងតែមានការចែងផ្សេងពីនេះនៅក្នុងធម្មនុញ្ញ ឬក្នុងបទបញ្ជាផ្សេងៗដែលបានបង្កើតដោយក្រុមប្រឹក្សា ឬគណៈកម្មាធិការប្រតិបត្តិ ។

២-សំលេងភាគច្រើនដែលមានចែងក្នុងធម្មនុញ្ញនេះ ឬក្នុងបទបញ្ជានានាដែលបានបង្កើតដោយក្រុមប្រឹក្សា ឬគណៈកម្មាធិការប្រតិបត្តិ គឺត្រូវសំដៅលើសមាជិកទាំងឡាយដែលមានវត្តមាន និងជាអ្នកបោះឆ្នោត ។

៣-ការបោះឆ្នោត នឹងមានសុពលភាពលុះត្រាណាតែសមាជិកភាគច្រើនរបស់ក្រុមប្រឹក្សា របស់គណៈកម្មាធិការ-ប្រតិបត្តិ ឬរបស់អនុគណៈកម្មាធិការដែលពាក់ព័ន្ធ មានវត្តមាន ។

## មាត្រា ៣០

១-អត្ថបទនៃការស្នើសុំធ្វើវិសោធនកម្មចំពោះធម្មនុញ្ញនេះ នឹងត្រូវបានអគ្គនាយក ធ្វើការទាក់ទងទៅរដ្ឋាភិបាលទាំងឡាយរបស់រដ្ឋជាសមាជិក យ៉ាងហោចណាស់រយៈពេល ៣ ខែ មុនការពិចារណារបស់ក្រុមប្រឹក្សា។

២-វិសោធនកម្ម នឹងចូលជាធរមាន ពេលដែលសមាជិករបស់ក្រុមប្រឹក្សាចំនួនពីរភាគបី បានអនុម័តយល់ព្រម ហើយ រដ្ឋជាសមាជិកពីរភាគបីព្រមទទួលយក ដោយស្របទៅតាមដំណើរការរដ្ឋធម្មនុញ្ញនៃរដ្ឋនីមួយៗ ប៉ុន្តែការធ្វើវិសោធនកម្មផ្សេងៗ ដែលពាក់ព័ន្ធនឹងករណីយកិច្ចថ្មីៗសំរាប់សមាជិកទាំងឡាយ នឹងចូលជាធរមានចំពោះសមាជិកណាមួយ នៅពេលដែលសមាជិកនោះព្រមទទួលយកវិសោធនកម្មទាំងនេះ។

## មាត្រា ៣១

ជំលោះណាមួយទាក់ទងនឹងការបកស្រាយ ឬការអនុវត្តន៍ធម្មនុញ្ញនេះ ដែលមិនបានដោះស្រាយដោយការចរចារ ឬដោយសេចក្តីសំរេចរបស់ក្រុមប្រឹក្សាតាមមតិភាគច្រើនពីរភាគបី នឹងត្រូវបញ្ជូនទៅតុលាការអន្តរ-ជាតិដើម្បីធ្វើការជំនុំជំរះ ស្របទៅតាមលក្ខន្តិកៈរបស់តុលាការ បើសិនរដ្ឋជាសមាជិកដែលពាក់ព័ន្ធទាំងឡាយមិនយល់ស្របចំពោះបែបបទផ្សេងទៀតនៃការដោះស្រាយក្នុងរយៈពេលសមស្របមួយទេ។

## មាត្រា ៣២

ដោយមានការអនុម័តយល់ព្រមពីសមាជិកពីរភាគបីរបស់ក្រុមប្រឹក្សា អង្គការអាចទទួលយកពីអង្គការ ឬ ទីភ្នាក់ងារអន្តរជាតិណាមួយនូវគោលបំណង និងសកម្មភាពទាំងឡាយដែលស្របតាមគោលបំណងរបស់អង្គការ ដូចជា សកម្មភាព ធនធាន និងករណីយកិច្ចផ្សេងៗ ដែលបានកំណត់ដោយកិច្ចព្រមព្រៀងអន្តរជាតិ ឬ ដោយការរៀបចំផ្សេងៗដែលព្រមទទួលយកទៅវិញទៅមករវាងអាជ្ញាធរមានសមត្ថកិច្ចរបស់អង្គការនីមួយៗ។

## មាត្រា ៣៣

ក្រុមប្រឹក្សា អាចសំរេចរំលាយអង្គការនេះបាន ដោយសំលេងឆ្នោតភាគច្រើនបីភាគបួននៃសមាជិករបស់ខ្លួន។

## មាត្រា ៣៤ (*)

ធម្មនុញ្ញនេះ នឹងចូលជាធរមានសំរាប់រដ្ឋាភិបាលសមាជិកទាំងឡាយនៃគណៈកម្មាធិការអន្តររដ្ឋាភិបាលសំរាប់ទេសន្តរប្រវេសន៍អឺរ៉ុប ដែលបានទទួលយកធម្មនុញ្ញនេះស្របតាមវដ្តធម្មនុញ្ញនីមួយៗរបស់ខ្លួន នៅថ្ងៃប្រជុំដំបូងរបស់គណៈកម្មាធិការនេះ បន្ទាប់ពី :

ក-សមាជិកគណៈកម្មាធិការយ៉ាងតិចពីរភាគបី

ខ-សមាជិកមួយចំនួន ដែលរួមវិភាគទានយ៉ាងតិច ៧៥ % នៃថវិកាផ្នែករដ្ឋបាល

បានជូនដំណឹងទៅនាយក អំពីការព្រមទទួលធម្មនុញ្ញនេះរបស់ពួកគេ ។

## មាត្រា ៣៥ (*)

រដ្ឋាភិបាលសមាជិកនៃគណៈកម្មាធិការអន្តររដ្ឋាភិបាលសំរាប់ទេសន្តរប្រវេសន៍អឺរ៉ុប ដែលមិនបានជូនដំណឹងទៅនាយក អំពីការទទួលយល់ព្រមរបស់ខ្លួនចំពោះធម្មនុញ្ញនៅថ្ងៃចូលជាធរមាននៃធម្មនុញ្ញនេះនៅរក្សាជាសមាជិករបស់គណៈកម្មាធិការសំរាប់រយៈពេលមួយឆ្នាំគិតចាប់ពីថ្ងៃចូលជាធរមាននោះមក បើសិនជាពួកគេរួមវិភាគទានចំពោះតំរូវការរដ្ឋបាលផ្សេងៗរបស់គណៈកម្មាធិការ ស្របទៅតាមកថាខ័ណ្ឌ ២ នៃមាត្រា ២៥ ហើយក្នុងរយៈពេលនេះ ពួកគេនៅរក្សាសិទ្ធិក្នុងការទទួលយកធម្មនុញ្ញនេះ ។

## មាត្រា ៣៦

អត្ថបទជាភាសាអង់គ្លេស បារាំង និងអេស្ប៉ាញ នៃធម្មនុញ្ញនេះ ត្រូវបានចាត់ទុកថាមានតំលៃត្រឹមត្រូវដូចគ្នា ។

---

(*) មាត្រា ៣៤ និងមាត្រា ៣៥ ត្រូវបានអនុវត្តបន្ទាប់ពីធម្មនុញ្ញចូលជាធរមាននៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៥៤ ។

# ពាក្យបច្ចេកទេសសំខាន់ៗ

- **ទេសន្តរប្រវេសន៍** : ដំណើរផ្លាស់ប្រទេស

  *Fr.* Migration *n. fém.* Déplacement d'une collectivité ou d'un groupe qui quitte un pays pour s'installer dans un autre, définitivement ou temporairement, © Hachette Livre, 1998.

  *En.* Migration: Movement of people from one country or region to another, Black's Law dictionary, 1999.

- **ទេសន្តរប្រវេសន្ត-សន្តី** : អ្នកដែលធ្វើដំណើរផ្លាស់ប្រទេស

  *Fr.* Migrant, ante *adj. et n.* Qui fait une migration, © Hachette Livre, 1998.
  *En.* Migrant

---

- **អន្តោប្រវេសន្ត-សន្តី** : ជនបរទេសដែលមកតាំងនៅក្នុងប្រទេសណាមួយ

  *Fr.* Immigrant, ante *adj. et n.* Qui immigre, © Hachette Livre, 1998.
  *En.* Immigrant: A person who arrives in a country to settle there permanently, Black's Law dictionary, 1999.

- **ធ្វើអន្តោប្រវេសន៍** : *Fr.* Immigrer *v. intr.* Entrer dans un pays étranger pour y habiter. Immigrer aux États-Unis. © Hachette Livre, 1998.
  *En.* To immigrate

- **អន្តោប្រវេសន៍** : *Fr.* Immigration
  *En.* Immigration

---

- **និរប្រវេសន្ត-សន្តី** : ជនដែលចេញទៅតាំងនៅប្រទេសក្រៅ

  *Fr.* Émigrant, ante *adj. et n.* Qui émigre, en parlant d'une personne. Population émigrante, © Hachette Livre, 1998.
  *En.* Emigrant: One person who leaves his or her country for any reason with the intent to establish a permanent residence elsewhere, Black's Law dictionary, 1999.

- **និរប្រវេសន៍** : ការចេញទៅតាំងនៅប្រទេសក្រៅ
- *Fr.* Émigration
  *En.* Emigration
- **ធ្វើនិរប្រវេសន៍** : ចេញទៅតាំងនៅប្រទេសក្រៅ
- *Fr.* Émigrer
  *En.* To emigrate or to migrate